# "ឡើងមាឃ" តាមទំនៀមអ្នកស្រុកអង្គរ

បើផ្អែកតាមប្រតិទិនចន្ទគតិ "មាឃ" ជាខែទី៣ ឬគេហៅថា "មាឃធំ" គឺជាដើមរដូវប្រាំង ដែលជាវេលាអ្នកស្រុកតែងប្រារព្ធពិធីបុណ្យទានផ្សេងៗ តាមទំនៀមទម្លាប់ស្រុករៀងៗខ្លួន។ ចំពោះអ្នកស្រុករស់នៅតំបន់អង្គរ ជារៀងរាល់ឆ្នាំនៅដើមខ្នើតក្នុងខែមាឃ គេតែងប្រារព្ធពិធីមួយហៅថា "ឡើងមាឃ"។ អ្នកភូមិភាគច្រើនប្រារព្ធពិធីនេះ នៅថ្ងៃ៣កើត ហើយអ្នកខ្លះពិធីនោះហៅថា "៣កើត មាឃធំ" ក៏មាន។[១] ទីតាំងដែលគេតែងប្រារព្ធពិធីឡើងមាឃ ឬ៣កើត មាឃធំនេះសោត ច្រើនតែជាសាលាបុណ្យ ឬសាលាសំណាក់ក្នុងភូមិ នៅតាមប្រាសាទ នៅខ្ទមអ្នកតា អ្នកតាក្នុងវត្ត ឬអ្នកតានៅតាមទីទួលនានា ហើយគេក៏ហៅពិធីនេះម្យ៉ាងទៀតដែរថា "ឡើងអ្នកតា"។

ជាការពិត ឡើងមាឃ ឬ៣កើតមាឃធំ ឬឡើងអ្នកតា គឺជាទំនៀមយ៉ាងសំខាន់ក្រៃលែងក្នុងជំនឿអ្នកស្រុករស់នៅតំបន់អង្គរ ដែលគេសង្កេតឃើញមានភូមិជាច្រើន ទាំងនៅតំបន់ភាគខាងលើ តំបន់កណ្ដាល និងតំបន់ខិតទៅក្បែរទន្លេសាបតែងប្រារព្ធតាមវេលាខាងលើពុំសូវខកខានឡើយ។[២] បច្ចុប្បន្នទិដ្ឋភាពឡើងមាឃនៅតំបន់អង្គដែលគេដឹងក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ គឺឡើងមាឃនៅមុខប្រាសាទអង្គរវត្ត នៅភូមិនគរក្រៅ នៅវត្តអធ្វារ និងនៅភូមិបង្កោង។ ប៉ុន្តែយ៉ាងណាក្ដីមានកន្លែងជាច្រើនទៀតដូចជា វត្តរុន ដូនឪ ត្រពាំងធំ ភូមិតាកាំ ភូមិក្បាលដំរី ភូមិទម្រឹង ភូមិប្រណីត ភូមិស្រែចង្ហូត ភ្នំក្រោម ចុងឃ្នាស និងកំពង់ភ្លុកជាដើម។ ចំពោះអ្នកស្រុក លុះត្រាតែប្រារព្ធឡើងមាឃរួចទើបគេធ្វើកិច្ចពិធី ឬបុណ្យទានផ្សេងៗទៀតដូចជា បូជាសពរួមគ្នា ចម្រើនអាយុ ចេញម្លប់កោរកំប៉ោយ (ផ្កាច់ជុក) និងជាពិសេសគឺ "លៀងមេមត់" តាមភូមិ ដែលគេកម្រឃើញប្រារព្ធមុនឡើងមាឃ។

---

[១] អាំង ជូលាន ២០១២-២០១៣: ៤៣-៤៨

[២] អ្នកស្រាវជ្រាវមើលឃើញថា ទំនៀមនេះពុំមែនមានតែក្នុងតំបន់អង្គរឡើយ តែឃើញប្រារព្ធក្នុងខេត្តភាគខាងជើងនៃកម្ពុជា ព្រមទាំងខេត្តខ្លះក្នុងដីថៃសព្វថ្ងៃដូចជា បុរីរម្យ និងសុរិន្ទ្រជាដើម (សូមអាន "៣កើត មាឃធំ" ដោយ អាំង ជូលាន ២០១២-២០១៣: ៤៣-៤៨)

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ជាទូទៅ ពិធីឡើងមាឃនៅមុខប្រាសាទអង្គរវត្តតែប្រារព្ធនៅថ្ងៃ៣កើត ក្នុងវេលារសៀល ដោយមានកិច្ចបញ្ចូលបញ្ជាន់រូប ហើយមានអ្នកភូមិមកពីជិតឆ្ងាយជុំវិញចូលរួមយ៉ាងច្រើនកុះករ។ មិនតែប៉ុណ្ណោះ តង្វាយនិងគ្រឿងសក្ការៈដែលរៀបក្នុងវេលានោះ ក៏ច្រើនសម្បូរហូរហៀរមានដូចជា ក្បាលជ្រូក (ឆ្នាំខ្លះមាន២ឬ៣គូ) មាន់ស្ងោ ផ្លែឈើ បង្អែមចម្អាប និងបាយស្រីច្រើនថ្នាក់ផង(រូបលេខ១-៤)។ ចំពោះរូបសំខាន់បំផុតដែលគេបញ្ចូលក្នុងពិធីនេះគឺតាពជ្យ បន្ទាប់មកគឺតាពេជ្រ តាឃ្លាំងមឿង និងអ្នកតាតូចធំផ្សេងៗទៀតនៅជុំវិញអង្គរ ឯភ្លេងប្រគំថ្វាយ គឺភ្លេងពិណពាទ្យ។ តាមទំនៀមពីបុរាណ នៅក្នុងវេលាបញ្ចូលបញ្ជាន់រូបនោះ អ្នកភូមិខ្លះតែងយក កាំបិត ពូថៅ ផ្គាក់... ដែលជាឧបករណ៍ប្រើប្រាស់ក្នុងការងារស្រែចម្ការយកមកសែនផងដែរ។[៣]



រូបលេខ១ ឡើងមាឃមុខអង្គរ, ឆ្នាំ២០១៩ (រូបថត៖ កាសែតនគរវត្ត)



រូបលេខ២ ឡើងមាឃមុខអង្គរវត្ត, ឆ្នាំ២០២២ (រូបថត៖ អាជ្ញាធរជាតិអប្សរា)





រូបលេខ៣ តង្វាយផ្សេងៗក្នុងពិធីឡើងមាឃមុខអង្គរ ឆ្នាំ២០២២ (រូបថត៖ អាជ្ញាធរជាតិអប្សរា)



រូបលេខ៤ តង្វាយក្នុងពិធីឡើងមាឃមុខអង្គរ ឆ្នាំ២០២៣ (រូបថត៖ អាជ្ញាធរជាតិអប្សរា)

---

[៣] បទសម្ភាសរបស់សារព័ត៌មាន "ថ្មីៗ" ផ្សាយថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០២០

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ចំពោះពិធីឡើងមាឃនៅភូមិនគរក្រៅ ដែលជាភូមិស្ថិតនៅកៀកនឹងបរិវេណអង្គរ ហើយអ្នកស្រុកភាគច្រើនរកស៊ីធ្វើស្រែនិងធ្វើជាកម្មករជួសជុលប្រាសាទ គឺប្រារព្ធធ្វើនៅខ្ទមអ្នកតា ក្បែរសាលាសំណាក់ ក្នុងថ្ងៃ៣កើត ដូចនៅអង្គរវត្តដែរ។ អ្នកតាសំខាន់នៅទីនោះគឺ អ្នកតាបាក់រទេះ (រូបលេខ៥)។ តាមសម្គាល់ ពិធីឡើងមាឃភូមិនេះធ្វើនៅមុខខ្ទមអ្នកតា ហើយមានភ្លេងពិទពាទ្យនិងកិច្ចបញ្ចូលបញ្ជាន់រូបផ្សេងៗចាប់ពីរសៀលរហូតដល់ព្រលប់ផងក៏មាន (រូបលេខ៦)។ សំណែនសំខាន់ដែលអ្នកភូមិតែងយកមកថ្វាយអ្នកតា គឺនំបញ្ចុក ដែលពីមុនគេតែងធ្វើតាមផ្ទះ។ ប៉ុន្តែសំណែនផ្សេងពីនោះមានដូចជា បាយម្ហូប នំចំណី និងផ្លែឈើ។ ក្រោយបញ្ចូលបញ្ជាន់រូបចប់សព្វគ្រប់ សំណែនទាំងឡាយនោះគេតែងយកទៅចាក់ចូលគ្នាក្នុងខ្ទមអ្នកតា។



រូបលេខ៥ ខ្ទមអ្នកតាបាក់រទេះ និងសាលាសំណាក់ កន្លែងប្រារព្ធពិធីឡើងមាឃ



រូបលេខ៦ ពិធីឡើងមាឃនៅមុខខ្ទមអ្នកតាបាក់រទេះ ក្នុងភូមិនគរក្រៅ

ចំណែកឯពិធីឡើងមាឃនៅវត្តអធ្វារ គឺធ្វើនៅក្នុងថ្ងៃ៣កើត ខែមាឃដែរ ហើយអ្នកស្រុកតែងរៀបចំគ្រឿងសំណែនផ្សេងៗថ្វាយបីកន្លែងគឺ ក្នុងប្រាសាទវត្តអធ្វារ ទួលដូនប៉ុក និងទួលតាមឿង ដែលជាកន្លែងសក្ការៈសំខាន់នៅទីនោះ។ ដំបូងគេធ្វើកិច្ចបញ្ចូលរូបនៅក្នុងប្រាសាទជាមុន (រូបលេខ៧-៨) ទើបបន្តទៅទួលដូនប៉ុក (រូបលេខ៩) និងបញ្ចប់នៅទួលតាមឿង (រូបលេខ១០)។ បំណងទូទៅនៃទំនៀមឡើងមាឃទីនេះ គឺដើម្បីសុំសេចក្តីសុខចម្រើន ចៀសឆ្ងាយពីជំងឺផ្សេងៗ និងបញ្ចៀសគ្រោះកាចចង្រៃផុតពីមនុស្សសត្វក្នុងភូមិ។ ភ្លេងដែលប្រគំថ្វាយក្នុងពិធី គឺភ្លេងអារក្ស ហើយគេសង្កេតឃើញមានរូបស្នងជាច្រើន។ ចំពោះអ្នកតាដែលគេបញ្ចូលមានដូចជា មហារាជ មហាជម្ពូ ស្តេចនាគខៀវ

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

នាគស នាគក្រហម យមភូបាល។ល។ ក្នុងពេលបញ្ចូលរូប អ្នកស្រុកច្រើនចូលទៅសុំទឹកមន្ត និងឱ្យអ្នកតាទាំងនោះស្ដោះផ្លុំព្យាបាលជំងឺជាដើម។ ជាចុងបញ្ចប់ គេយកសំណែនផ្សេងៗចាក់ចូលសង្សឹក រួចធ្វើកិច្ចបញ្ជូន។



រូបលេខ៧-៨ កិច្ចបញ្ចូលរូបនៅក្នុងប្រាសាទអធ្វារ



រូបលេខ៩-១០ កិច្ចបញ្ចូលរូបនៅក្នុងប្រាសាទទួលដូនប៉ុក និងទួលតាមឿង

ដោយឡែកពិធីឡើងមាឃភូមិបង្កោង ដែលស្ថិតក្នុងឃុំអំពិល ស្រុកប្រាសាទបាគង ជាពិធីមួយដែលពុំកំណត់យកថ្ងៃដាក់លាក់ "៣កើតខែមាឃ" ដូចភូមិផ្សេងៗទេ តែពិធីក្នុងភូមិនេះគេក៏សង្កេតឃើញប្រារព្ធធ្វើពុំហួសខែមាឃ ឬឆ្លងចូលខែផល្គុនដែរ ហើយធ្វើពីរថ្ងៃ។ តាមទម្លាប់ នៅមុនថ្ងៃប្រារព្ធពិធី អ្នកភូមិតែងជួបជុំគ្នានៅត្រពាំងធំមួយឈ្មោះថា "ត្រពាំងបឹង" ដើម្បីចុះចាប់ត្រីយកទៅធ្វើម្ហូប ជាពិសេសធ្វើសម្ងំបញ្ចុកសម្រាប់រៀបចំឡើងអ្នកតា និងប្រគេនព្រះសង្ឃក្នុងថ្ងៃបន្ទាប់។ ចំពោះត្រពាំងនេះ អ្នកស្រុកទុកដូចជាសម្បត្តិរួមយ៉ាងសំខាន់របស់សហគមន៍ ហើយគេពុំដែលហ៊ានល្មើសទំនៀមចុះចាប់ត្រី

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ត្រពាំងនោះមុនថ្ងៃកំណត់ឡើយ។[៤] មិនតែប៉ុណ្ណោះ ការចាប់ត្រីក្នុងត្រពាំងសហគមន៍នោះសោត គេឱ្យប្រើតែឧបករណ៍នេសាទបុរាណរួមមាន សំណាញ់ មង អង្រុត និងឈ្នាងជាដើម (រូបលេខ១១)។ ត្រីដែលចាប់បានគេអាចយកទៅផ្ទះរៀងខ្លួន តែចុងក្រោយគេបើកសម្រាស់ដែលស្ថិតនៅកណ្ដាលត្រពាំង ហើយនាំគ្នាអូសព័ទ្ធចាប់ត្រីនោះទុកជាត្រីរួមសម្រាប់ធ្វើម្ហូបនៅសាលាបុណ្យ។



រូបលេខ១១ អ្នកភូមិចុះចាប់ត្រីក្នុងត្រពាំងបឹងនៅភូមិបង្កោង

លុះស្អែកឡើង អ្នកភូមិចាប់ផ្ដើមរៀបចំម្ហូបចំណី ចង្ហាន់ព្រះសង្ឃ និងគ្រឿងសក្ការៈព្រមទាំងស្រូវរៀងៗខ្លួនយកទៅកាន់សាលាបុណ្យ។ នៅក្នុងបរិវេណសាលាបុណ្យគេតែងរៀបចំឱ្យមានភ្នំខ្សាច់ និងពនទេវតាតាមទិសទាំង៨។ លុះដល់វេលារសៀល អាចារ្យចាប់ផ្ដើមធ្វើកិច្ចប្រុងពលី លើកទង់ បួងសួងសុំសេចក្ដីសុខ បំបួសភ្នំខ្សាច់ ភ្នំស្រូវ។ លុះវេលាព្រលប់ គេនិមន្តព្រះសង្ឃមកចម្រើនព្រះបរិត្តទៅតាមទំនៀមព្រះពុទ្ធសាសនា។ ព្រឹក

[៤] ខៀវ ច័ន្ទ ២០១៣-២០១៤: ៣៨-៤៣ និងក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ២០១៧: ១៧៧-១៧៨

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ឡើងជាថ្ងៃបញ្ចប់ គេធ្វើពិធីរាប់បាត្រធ្វើបុណ្យ។ ចំណែកឯភ្នំខ្សាច់ និងស្រូវដែលអ្នកភូមិយកមកចូលរួមនោះក៏ធ្វើកិច្ចផ្សឹកក្នុងថ្ងៃបញ្ចប់នេះដែរ។ ស្រូវទាំងនោះ គេវេរប្រគេនព្រះសង្ឃទុកនៅវត្ត។ ចំណែកឯកិច្ចបញ្ចូលបញ្ឆាន់រូប គឺពុំឃើញមានប្រារព្ធដូចនៅមុខប្រាសាទអង្គរវត្ត ភូមិនគរក្រៅ ឬនៅវត្តអធ្វារឡើយ។ សូមរំឭកថា ពិធីឡើងមាឃនៅភូមិបង្កោងឆ្នាំនេះ ប្រារព្ធនៅថ្ងៃ១១-១៣កើត ខែមាឃ ត្រូវនឹងថ្ងៃទី១-៣ ខែកុម្ភៈ ឆ្នាំ២០២៣។

សរុបខ្លីមក ឡើងមាឃ ឬ៣កើតមាឃធំ ឬឡើងអ្នកតា តាមទំនៀមអ្នកស្រុកអង្គរបង្ហាញពីការបញ្ចប់រដូវធ្វើស្រែ ដ្បិតគេតែងឃើញវត្តមានស្រូវប្រើជាវត្ថុសំខាន់។ សូមកុំភ្លេចថាខ្មែរទុកស្រូវជាដំណាំខ្ពង់ខ្ពស់ក្នុងវប្បធម៌ ជាពិសេសប្រដូចស្រូវទៅនឹងមនុស្សស្រី។[៥] គំនិតនេះ គេអាចសិក្សាលម្អិតនៅតាមភូមិផ្សេងៗទៀត ដើម្បីយកជាមូលដ្ឋានស្រាវជ្រាវវែងឆ្ងាយបាន។ ប៉ុន្តែយ៉ាងណាក្តី អ្នកស្រុកពន្យល់ថាទំនៀមឡើងមាឃសព្វថ្ងៃ បានប្រែប្រួលប្តូរផ្លាស់បន្តិចម្តងៗ បើធៀបនឹងរយៈពេលប្រហែល១០ ឬ២០ ឆ្នាំមុន៕

[៥] ស៊ុន ចាន់ដឹប ២០០៦-២០០៧: ៥០-៥៤ និង អាំង ជូលាន, គង់ វីរៈ, រស់ សុខុម ២០០៧: ២៩៣

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

# ឯកសារយោង


ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

២០១៧, *បញ្ជីសារពើភណ្ឌមត៌កវប្បធម៌អរូបីកម្ពុជា*, ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ, ភ្នំពេញ

ខៀវ ច័ន្ទ

២០១៣-២០១៤, "សម្បត្តិរួមនៃសហគមន៍", *កម្រងអត្ថបទក្នុងបណ្ដាញព័ត៌មានវប្បធម៌ខ្មែរ*, លេខ៩, ទំ.៣៨-៤៣, Friend of Khmer Culture, ភ្នំពេញ

ស៊ុន ចាន់ដឹប

២០០៦-២០០៧, "ស្រូវកញ្ចើ", *កម្រងអត្ថបទក្នុងបណ្ដាញព័ត៌មានវប្បធម៌ខ្មែរ*, លេខ២, ទំ.៥០-៥៤, Friend of Khmer Culture, ភ្នំពេញ

អាំង ជូលាន

២០១២-២០១៣, "៣កើត មាឃជំ", *កម្រងអត្ថបទក្នុងបណ្ដាញព័ត៌មានវប្បធម៌ខ្មែរ*, លេខ៨, ទំ.៤៣-៤៨, Friend of Khmer Culture, ភ្នំពេញ

អាំង ជូលាន, គង់ វីរៈ រស់ សុខុម

២០០៧, "ពូនភ្នំស្រូវនៅតំបន់ភ្នំបូក, អង្គរ" *ឧទ័យ*, លេខ៨, ទំ.២៩៣-៣០៥, Friend of Khmer Culture, ភ្នំពេញ


អត្ថបទដោយ៖ ហៀន សុវណ្ណមរកត